# ការសំភាសន៍របស់បងស្រី គ្រឿន សុផល

**កៈ អ្នកធ្វើការសំភាសន៍ កុសល្យ វឌ្ឍនៈនិមល ខៈ អ្នកត្រូវគេសំភាសន៍ គ្រឿន សុផល**

## ការសង្ខេបរបស់បងស្រី គ្រឿន សុផល

ការសង្ខេបពីខ្ញុំនិមល គាត់បានឆ្លងកាត់ភាពក្រីក្រមកដោយកាតស៊ូខ្លាំងមែនទែន គាត់បានធ្វើនាក់បុះរើគេរាប់ឆ្នាំ តែដោយសារការតស៊ូរបស់គាត់សព្វថ្ងៃគាត់ធូធាមែនទែន ហើយគាត់ក៏យល់ពីនាក់ក្រយ៉ាងច្បាស់។

កៈ អញ្ចឹងជាដំបូងខ្ញុំសូមអរគុណបងស្រីដែរបានអនុញ្ញាតិដើម្បីអោយខ្ញុំមកសំភាសន៍ថ្ងៃហ្នឹង។ ហើយបងខ្ញុំឈ្មោះកុសល្យ វឌ្ឍនៈនិមល ជាអ្នកសំភាសន៍បង។ ហើយទីតាំងដែរសំភាសន៍គឺនៅភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ហើយថ្ងៃខែដែរសំភាសន៍គឺនៅថ្ងៃទី ១០ ខែ ០៦ ឆ្នាំ ២០១៨។ ហើយបងអើ ការសំភាសន៍នេះគឺត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅសហរដ្ឋអាមេរិកដែរមានឈ្មោះថា BYU ។ ហើយគោលបំណងរបស់សាលាគឺចង់ជួយដល់ប្រជាជនខ្មែរទាំងអស់ដើម្បីពួកគាត់អាចមានឱកាសថែរក្សារប្រវត្តិក្រុមគ្រួសារដើម្បីអោយកូនចៅជំនាន់ក្រោយៗទៀតអាចមានឱកាសរៀនពីជីវិតរបស់បងផ្ទាល់ហាបង។ ហើយបងអើ ជាដំបូងខ្ញុំចង់សួរបងថា តើបងមានឈ្មោះពេញឈ្មោះនៅក្នុងអតសញ្ញាតិបទបងឈ្មោះអីគេដែរ?

ខៈ គ្រឿន សុផល។

កៈ គ្រឿន សុផល?

ខៈ ចាស។

កៈ ហើយបងមានឈ្មោះហៅក្រៅហ្អេស?

ខៈ អត់ទេ មានតែឈ្មោះមួយហ្អេ។

កៈ តាំងពីក្មេងរហូតមកដល់ឥឡូវបងឈ្មោះសុផលរហូត?

ខៈ ចាស ឈ្មោះគ្រឿន សុផលរហូត។

កៈ ចាសបងចាស។ ហើយអើ បើគិតមកដល់ឥឡូវឆ្នាំនេះបងមានអាយុមាណហើយ?

ខៈ បងមានអាយុ៥០សិបឆ្នាំហើយ។

កៈ ៥០សិបឆ្នាំហើយ?

ខៈ ចាស។

កៈ ចាស តើបងចាំថាបងកើតនៅថ្ងៃណា? ខែណា? ឆ្នាំណាហ្អេស?

ខៈ ពេលហ្នឹងខ្ញុំអត់ចាំដែរ ព្រោះម៉ែខ្ញុំគាត់នៅតាមស្រុកស្រែអញ្ចឹង គាត់អត់ចាំខែឆ្នាំខ្ញុំហ្អេស។

កៈ ចាស។

ខៈ ចាស ប៉ុន្តែបើឆ្នាំខ្មែរ ឮគាត់និយាយថាអើ កត្តិក កើតខែកត្តិក។

កៈ ខែ កត្តិក ចុះបងចាំឆ្នាំសត្វអីហ្អេស?

ខៈ អើ ឆ្នាំ អើឆ្នាំមមី។

កៈ ឆ្នាំមមី?

ខៈ ហ្នឹងហើយ។

កៈ ខ្ញុំឆ្នាំមមីដែរ ហិហិហិ។

ខៈ ហិហិហិ។

កៈ តែបងមមីជូរមុន។

ខៈ ចាស ជូរមុន។

កៈ ចាស ភាគច្រើនមនុស្សឆ្នាំមមីចិត្តល្អ។

ខ៖ ហ្នឹងហើយចិត្តល្អ។

ក៖ ហិហិ ហ្នឹងហើយខ្ញុំដឹងខ្លួនឯង តែឆាប់ខឹង។

ខ៖ ឆាប់ខឹង ឆាប់ៗបាត់។

ក៖ ឆាប់បាត់ ហិហិ។

ខ៖ ឆាប់បាត់ទេ។

ក៖ ចាស ហើយអើ តើបងចាំពីកន្លែងកំណើតរបស់ខ្លួនឯងហ្អេស? ដូចជានៅភូមិអី?

ខ៖ ចាំ។

ក៖ ស្រុកអីអញ្ចឹងហា?

ខ៖ ខ្ញុំនៅអើ ខេត្តកណ្ដាល ស្រុកស្អាង ឃុំកោះខែល ភូមិអរជូរ។

ក៖ ភូមិអរជូរ?

ខ៖ ចាស។

ក៖ ចាសបង។ ចុះបងអើ មានបងប្អូនចំនួនមាណនាក់ដែរ?

ខ៖ បងប្អូនខ្ញុំ៧នាក់។អើ សព្វថ្ងៃនៅតែ៦នាក់ហ្អេស។

ក៖ ស្លាប់អស់ម្នាក់ហើយ?

ខ៖ អើ អត់ទេ អត់ដឹងថាគាត់ទៅខាងណា គាត់អត់ដឹងថាគាត់ស្លាប់ឬមួយគាត់នៅ។

ក៖ ចាស។

ខ៖ ព្រោះបាត់តាំងពីជំនាន់ពលពតហ្អែរ។

ក៖ ហ្អែរ ហើយរកអត់ឃើញ?

ខ៖ រកអត់ឃើញ?

កៈ ចាស ហើយអើ ប្រុសមាណស្រីមាណដែរបង?

ខៈ ប្រុសអើ ប្រាំ ប្រុសអើបួននាក់ ស្រីពី។

កៈ ស្រីពី?

ខៈ ចាស។

កៈ ចាស ហើយប្រាំមួយនាក់រាល់ថ្ងៃនៅរស់ទាំងអស់?

ខៈ នៅរាល់ទាំងអស់។

កៈ ចាស ហើយតើបងជាកូនទីមាណដែរ?

ខៈ ខ្ញុំជាកូនទីប្រាំមួយ។ ពៅគេ។

កៈ កូនទីប្រាំមួយ? ពៅគេ? ហិហិហិ។

ខៈ ចាស។

កៈ ហើយ តើបងអាចរៀបរាប់ឈ្មោះបងប្អូនបងតាំងពីកូនទីមួយរហូតដល់ពៅគេបានហ្អេស?

ខៈ បាន។

កៈ ចាស។

ខៈ យកពីទីប្រាំពីឬពីទីមួយមក?

កៈ ចាស ពៅបងគេរហូតដល់ពៅគេ។

ខៈ រហូតដល់ប្រាំពីអើ ទីថាបាត់ហ្នឹងហា?

កៈ ចាស។

ខៈ ទី អើ ទីមួយអើ គាត់ឈ្មោះអើ បង បងសិន។

កៈ បង សិន?

ខ៖ ចាស ទីពីគាត់ឈ្មោះបង ស្រេន។

ក៖ បងស្រេន?

ខ៖ ទីបីគាត់ឈ្មោះបង ងិត។

ក៖ បង ងិត?

ខ៖ ចាស ទីបួនគាត់ឈ្មោះ បង ឡៅ។

ក៖ បង ឡៅ?

ខ៖ អើ ប្រាំ។

ក៖ ប្រាំ?

ខ៖ ឈ្មោះបង គ្រី។

ក៖ បង គ្រី?

ខ៖ ទីប្រាំមួយឈ្មោះ ខ្ញុំឈ្មោះផល។

ក៖ ឈ្មោះ ផល?

ខ៖ ចាស អស់ហើយ។

ក៖ ទី បងដែរបាត់ខ្លួន?

ខ៖ បាត់ខ្លួននិយាយពីមុនហ្អរ។

ក៖ ហ្អរ?

ខ៖ ឈ្មោះបង ស្រិន។

ក៖ ចាសចាសបង។ ហើយអើ តើបងនៅចងចាំសាច់រឿងអីខ្លះនៅពេលបងនៅក្មេងៗជាមួយគ្នារ ឬក៏បងធ្លាប់លេងឬក៏មានអនុស្សាវរីយ៍អីខ្លះជាមួយបងប្អូនបងហ្អេស?

ខ៖ ខ្ញុំមានច្រើន កាលពីខ្ញុំនៅតូច ខ្ញុំរៀនអត់បានជ្រៅហ្អេស។

ក៖ ចាស។

ខ៖ បងខ្ញុំគាត់អោយ អោយខ្ញុំទៅឃ្វាលគោអញ្ចឹងទៅ។

ក៖ ចាស។

ខ៖ ហើយអើ ឃ្វាលគោដល់មួយជន្ទប់អីអញ្ចឹង គាត់អោយខ្ញុំទៅឃ្វាលគោហា។

ក៖ ចាស។

ខ៖ ឃ្វាលគោហើយ ដល់ពេលថ្ងៃខ្លះទៅខ្ញុំអត់ចង់ទៅខ្ញុំគេចដែរ តែអត់ចង់ទៅបងវៃហើយ។

ក៖ ហិហិហិ។

ខ៖ វៃអោយខ្ញុំទៅឃ្វាលគោ។

ក៖ ចាស។

ខ៖ ទៅឃ្វាលគោអញ្ចឹងទៅ ទៅអញ្ចឹងទៅលេងជាមួយគេក្មេងៗអញ្ចឹងហា។

ក៖ ចាស។

ខ៖ ជំនាន់ហ្នឹងលេងដូចថាអត់សូវចេះប្រកាន់ហ្អេស ក្មេងៗដូចគ្នាហ្នឹង។

ក៖ ចាស។

ខ៖ ចាស ខ្ញុំឡើងដើមឈើលេងអញ្ចឹងទៅ ជូនកាលគេឃើញខ្ញុំនេះអញ្ចឹងទៅ គេធ្វើបាបគេដាក់អាដបទឹកហា។

ក៖ ចាស។

ខ៖ អោយនោមដាក់ក្នុងដបហើយអោយខ្ញុំញាំ។

ក៖ ហ្អឺ ?

ខ៖ ខ្ញុំអត់ដឹងហ្អេ។

ក៖ ហិហិហិ ធ្វើបាបខ្លាំងម៉ង?

ខ៖ ធ្វើបាប ខ្ញុំដល់ពេលខ្ញុំហូបហើយបានគេប្រាប់។

ក៖ ហ្អរ?

ខ៖ ក្មេងៗដូចគ្នារហ្នឹងហា។

ក៖ ចាស។

ខ៖ ចាស ហើយគាត់អើ ពេលហ្នឹងគាត់សើចខ្ញុំ។

ក៖ ចាស។

ខ៖ ដល់តែពេលដ៏ខ្ញុំរៀងដូចធំតិច ខ្ញុំដូចថាជិះកង់ទៅ ជិះកង់ទៅស្រែហា។

ក៖ ចាស។

ខ៖ ជិះកង់ទៅស្រែ ពេលខ្ញុំមកត្រឡប់មកផ្ទះវិញហា អើ មានរទេះមួយហា។

ក៖ ចាស។

ខ៖ រទេះហ្នឹងដឹកចំបើងខ្ពស់ៗហា នៅស្រុកខ្ញុំហា។

ក៖ ចាស។

ខ៖ ដល់តែពេលហើយខ្ញុំកង់ធ្លាក់ច្រវ៉ាក់។

ក៖ ហ្អរ?

ខ៖ ពេលខ្ញុំកង់ធ្លាក់ច្រវ៉ាក់ហ្នឹង ខ្ញុំអោនដាក់អើ ដាក់ច្រវ៉ាក់កង់។

ក៖ ចាស។

ខ៖ ដាក់ច្រវ៉ាក់កង់ ពេលនោះហា ខ្ញុំអត់ដឹងថាសំលេងហ្នឹង រទេះហ្នឹងអត់មានឮអីតិចហ្អេស រទេះហ្នឹងក្រលាប់មកពីលើកង់ខ្ញុំហា។

ក៖ ចាស។

ខ៖ ពីលើកង់ខ្ញុំទៅ ខ្ញុំអត់ដឹងថារទេះហ្នឹងក្រឡាប់ពីលើទៀត។

ក៖ ចាស។

ខ៖ ទាល់តែពេលខ្ញុំដាក់ច្រវ៉ាក់ហើយខ្ញុំងើប ខ្ញុំងើបឡើងមកខ្ញុំបុកអាចំបើងហ្នឹង បានខ្ញុំដឹងថាមានរទេះក្រឡាប់។

ក៖ ហិហិហិ។

ខ៖ ហើយដល់ពេលហ្នឹង គាត់នាក់បរទេះហ្នឹងហា ក៏គាត់អត់ដឹងថាខ្ញុំ មានខ្ញុំនៅក្នុងហ្នឹងទៀត។

ក៖ ហ្អឺ?

ខ៖ ទាល់តែខ្ញុំដើរភ្ញាក់ដើរចេញពីចំបើងមកបានគាត់ដឹងថាខ្ញុំ មានមនុស្សក្នុងហ្នឹង។

ក៖ បានដឹងថាមានមនុស្សក្នុងហ្នឹង?

ខ៖ ចាស គាត់ភ្ញាក់ផ្អើលហាណាពេលហ្នឹងហា។

ក៖ ចាស។

ខ៖ ហើយអើ ហើយគាត់ថាអើ មិនគួណាមានមនុស្សហ្អេ ហើយអត់ស្លាប់ទៀត។

ក៖ ចាស។

ខ៖ ចុះចំបើង។

ក៖ ចាស។

ខ៖ ហើយមានកង់ទ្រអញ្ចឹងហា ហើយយើងមានកន្លែងប្រឡោះចេញបានហ្អរ។

ក៖ ចាស។

ខ៖ គាត់ស្ទើចហា។

ក៖ ចាស។

ខ៖ ដំអញ្ចឹងគាត់ ហើយកង់ខ្ញុំហ្នឹងហា ដៃកង់ឡើងរៀចអស់។

ក៖ ចាស។

ខ៖ តួកង់ឡើងរៀចហើយ តែវានៅប្រឡោះប្រហើបយើងអាចចេញបាន។

ក៖ ចាស។

ខ៖ អញ្ចឹងក៏ធ្វើអោយមានភាពមួយអស្ចារ្យឆ្ងល់ហា គាត់ឆ្ងល់ហា។

ក៖ ចាសចាស។

ខ៖ ចាស រំលងអើ ខ្ញុំបានអើ ប្រហែលជា១៦ឆ្នាំ ១៦ឆ្នាំខ្ញុំនៅទៅៗ បងស្រីហា។

ក៖ ចាស។

ខ៖ ទៅបងស្រីនៅទន្លេ ផ្ទះខ្ញុំក្បែរទន្លេហា ព្រឹកឡើងគេចូលចិត្តទៅដងត្រីពេលព្រឹកហា ដើម្បីបានត្រីបណ្តូលល្តៅហ្នឹង។

ក៖ ចាស។

ខ៖ យកមកហូបយកមកអីអញ្ចឹងហា។

ក៖ ចាស។

ខ៖ ហើយខ្ញុំទៅដងពីនាក់អើ មិត្តភក្រ័មួយហ្នឹងគាត់អត់ចេះហែលទឹកហ្អេស។

ក៖ ចាស។

ខ៖ ខ្ញុំហ្នឹងក៏ដង ខ្ញុំខ្លាច ខ្ញុំខ្លាចទឹកជ្រៅ ខ្ញុំខ្លាចមានក្រពើ កាលនៅក្មេងៗចេះតែគិតទៅណា។

កៈ ចាស។

ខៈ ដំពេលគាត់ហ្នឹង គាត់ គាត់ គាត់អត់ខ្លាចគាត់នៅកណ្តាល ខ្ញុំនៅគៀន។

កៈ ហិហិហិ។

ខៈ ដល់តែពេលគាត់ដើរទៅវាមានអន្លង់មួយហា វានៅក្នុងហ្នឹងហា។

កៈ ចាសបង។

ខៈ ខ្ញុំអត់ដឹងថាខ្ញុំធ្វើមិចទេ កូនហ្នឹងគាត់ចេះតែលើកដៃខ្វៃៗអោយខ្ញុំជួយហា។

កៈ ចាស។

ខៈ តែខ្ញុំហ្នឹងរកវីធីសាសន៍ហា ទៅជួយគាត់ ខ្ញុំអត់យកអាស្បៃហ្នឹងបោះហ្អែស ខ្ញុំរត់ទៅចាប់ជាន់អើ ទាញគាត់មកហា។

កៈ ចាស។

ខៈ គាត់ហ្នឹងគាត់អត់ដឹងថាខ្ញុំជួយគាត់ក៏វីធីសាសន៍ធ្វើមិចហ្អែស គាត់ឡើងជាន់ពីខ្ញុំ។

កៈ ហ្អរ?

ខៈ ជាន់ខ្ញុំដើម្បីដកដង្ហើមគាត់ហា តែខ្ញុំមានអារម្មណ៍មួយគិតថា ខ្ញុំត្រូវរកធ្វើមិចហ្អេ? ខ្ញុំមានតែវីធីសាសន៍មួយគឺធាក់គាត់ទៅគៀន។

កៈ ចាស។

ខៈ ចេះខ្ញុំនឹកឃើញអាវីធីហ្នឹង ខ្ញុំធាក់គាត់ទៅគៀនទៅបានខ្ញុំស្រវ៉ារកដង្ហើមរួចហា។

កៈ ហ្អរ?

ខៈ ចាស។

កៈ អញ្ចឹងបានគេអត់អោយជួយមនុស្សលង់ទឹកហា។

ខ៖ ចាស ហ្នឹងហើយពេលខ្ញុំជួយបានគាត់មក ថាខ្ញុំដូចរស់ឡើងវិញអញ្ចឹងហា ត្រដេត្រដរស្រួលហាបានដង្ហើមមកវិញស្រួលហា។

ក៖ ចាស។

ខ៖ ដូចថាខ្ញុំចង់ ដង្ហើមចង់ទៅហើយ។

ក៖ ចាស។

ខ៖ ដូចថាក្នុងទឹកវាហាប់ហា ធម្មតាគេជាន់យើងដើម្បីគេរកដង្ហើមខ្លួនគេហា។

ក៖ ចាស។

ខ៖ ប៉ុន្តែអាមនុស្សយើង ទាំងពីនាក់ជាន់ក៏នៅតែកាន់តែលិចទៅដែរ។

ក៖ ហិហិហិ ចាស ហ្នឹងហើយ។

ខ៖ ព្រោះជើងវាអត់ដល់ដីដូចគ្នារ។

ក៖ ចាសចាសបង។

ខ៖ ហ្អឺ។

ក៖ អញ្ចឹងបទពិសោធន៍បង?

ខ៖ ខ្ញុំមានច្រើនណាស់។

ក៖ មានសប្បាយ?

ខ៖ មានសប្បាយ ចាស ហើយខ្ញុំទាំង។

ក៖ មានទាំងពិបាក?

ខ៖ ចាស ហើយខ្ញុំមានមួយទៀត ខ្ញុំរៀនជិះម៉ូតូខ្ញុំអត់ចេះជិះហ្អេស។

ក៖ ចាស។

ខ៖ ខ្ញុំរៀនជិះម៉ូតូទៅ ជាមួយក្មួយទៅ គេបង្រៀនទៅ បង្រៀនហា។

ក៖ ចាស។

ខ៖ គាត់ថាអើ ដល់ពេលខ្ញុំចេះជិះម៉ូតូទៅ ខ្ញុំបង្រៀនមីងឯង។

ក៖ ចាស។

ខ៖ បង្រៀនទៅ គាត់បង្រៀនទៅ គាត់អោយខ្ញុំជិះ។

ក៖ ហ្អរ ចាស។

ខ៖ ហើយខ្ញុំជិះទៅ គាត់មិនទាន់ឡើងផងខ្ញុំមូលហ្អែទៅ ទៅចោលគាត់ទៅ ហើយចេះតែទៅហើយ។

ក៖ ហិហិហិ។

ខ៖ ហើយក្មួយខ្ញុំចេះតែទាញទៅ។

ក៖ ចាស។

ខ៖ ទាញតាមក្រោយហ្នឹង ថាអោយទាញទៅ ថាអោយខ្ញុំហ្នឹងបង្អប់ ខ្ញុំអត់ដឹងថាបញ្ឈប់ត្រង់ណាហ្អែស ខ្ញុំអត់ចេះបិទអត់ចេះបើកទេ ចេះតែទៅមុខហ្អរ។

ក៖ ចាស។

ខ៖ ទៅទៅ ដល់តែពេលខ្ញុំស្លន់ពេក ខ្ញុំចេះតែមូលទៅអញ្ជឹងទៅ មកថយក្រោយ រលត់ឯងទៅ។

ក៖ ហិហិហិ បទពិសោធន៍សប្បាយ។

ខ៖ ចាស សប្បាយហើយក៏មាន ខ្ញុំដ៏ពេលខ្ញុំធំឡើង ខ្ញុំមានភាពមួយគិតថា អើ ខ្ញុំមានភាពអស្ចារ្យហេតុអីបានអោយខ្ញុំមកព្រះវិហារបានស្គាល់ព្រះវិហារ បើសិនជានេះខ្ញុំចង់ស្លាប់ប៉ុន្មានដងហើយ។

ក៖ ហ្អរ។

ខ៖ បើបញ្ហាខ្ញុំជួបហា។

ក៖ គ្រោះថ្នាក់រហូត។

ខ៖ ចាស ប្រហែលជា ខ្ញុំមានគ្រោះថ្នាក់ច្រើន ប៉ុន្តែដូចថាអើ ខ្ញុំធ្លាប់ជិះម៉ូតូហា ជិះម៉ូតូមួយម៉ាវាវ អញ្ចឹងហា នៅលើផ្លូវហ្នឹង ខ្ញុំអត់មានឃើញអីសោះ ឃើញតែរូបខ្ញុំម្នាក់ឯងជិះហ្អេស។

ក៖ ចាស។

ខ៖ ដល់ពេលខ្ញុំចេញផុតពីឡានហ្នឹងបានដឹងថា?

ក៖ មានឡាន?

ខ៖ មានឡានហា។

ក៖ ហ្អរ ចាស។

ខ៖ ហើយខ្ញុំអត់ដឹងថាខ្ញុំប្របេះជាមួយឡានហ្នឹងយ៉ាងមិចទេ? ខ្ញុំអត់ដឹងហ្អេ ព្រោះខ្ញុំមើលអត់ឃើញសោះ។ អញ្ចឹងបានជាខ្ញុំនឹកឃើញថាចេះ ប្រហែលព្រះដឹកនាំខ្ញុំដើម្បីអោយ ដើម្បីទុកជីវិតអោយខ្ញុំមកកាន់ព្រះវិហារហើយ។ ខ្ញុំមកព្រះវិហារហ្នឹងក៏មានការចៃដន្យដែរ ព្រោះខ្ញុំអត់បានដឹងអត់បានស្គាល់អត់បាននេះហ្អេដំបូងហ្អរ។

ក៖ ចាស។

ខ៖ ខ្ញុំអត់ដឹងទេ ព្រោះខ្ញុំជិះកង់ ខ្ញុំរៀនជិះកង់ដំបូងហ្អេ។

ក៖ ចាស។

ខ៖ ជិះកង់ គេទិញអោយខ្ញុំហា គេអោយខ្ញុំជិះលេងសាកអញ្ចឹងទៅណា។

ក៖ ចាស។

ខ៖ កង់ជំនាន់ហ្នឹង គេហៅថាអាកង់ដៃត្រង់ហ្អរ។

ក៖ ចាស។

ខ៖ ហ្នឹងល្បីហា។

ក៖ ចាស។

ខ៖ ដំហើយខ្ញុំជិះមកជាមួយមិត្តភក្រ័ទៅ គេថាខ្ញុំមានស្គាល់ព្រះវិហារមួយ មានកន្លែងហ្នឹងអើ ចេញចូលសិរីអីអញ្ចឹងហា ដូចគេអត់អើ អត់រើសអើងហា។

ក៖ អត់ថាអត់អីហា។

ខ៖ ចាស អត់ថាអត់អីហា ខ្ញុំហ្នឹងក៏ចូលមកតាមទៅ តាមទៅក៏ជួបអែលឌើរជួបអីទៅ គាត់ទំនាក់ទំនងអោយខ្ញុំរៀនសូត្រទៅ ដំពេលខ្ញុំចេះតែទៅអញ្ចឹងទៅ សាខាខ្ញុំចូលដំបូងមានតែពីហ្អេខ្ញុំចូលហា។

ក៖ ចាស។

ខ៖ សាខា សាខាទីពីហា ខ្ញុំចូលហា។

ក៖ ចាស។

ខ៖ ខ្ញុំស្គាល់ដំបូងនៅទួលគោកហា។

ក៖ ចាសបង។

ខ៖ ចាស បានដំពេលហើយខ្ញុំចេះតែមកព្រះវិហារអញ្ចឹងទៅ មកៗក៏បានស្គាល់គ្រួសារខ្ញុំដែរ។

ក៖ ចាស ហើយចុះអើ បងប្អូនរបស់បងវិញអើ រាល់ថ្ងៃគាត់រស់នៅកន្លែងណាខ្លះដែរ?

ខ៖ អើ បងប្អូនខ្ញុំនៅស្រុកទាំងអស់ ប៉ុន្តែអើ គាត់បានម្នាក់គាត់មកភ្នំពេញ នៅហ្នឹងគាត់នៅជួលផ្ទះគេដែរទេ។

ក៖ ចាស។

ខ៖ ចាស ប៉ុន្តែគាត់បានចូលព្រះវិហារដែរ តែឥឡូវហ្នឹងគាត់ចាកចេញពីព្រះវិហារ ខ្ញុំចេះតែមានការអូសទាញគាត់ដែរហា។

ក៖ ចាសបង។

ខ៖ ប៉ុន្តែដូចថាការល្បងគាត់វាច្រើនដែរ ខ្ញុំ។

ក៖ វាពិបាក?

ខ៖ ចាស វាពិបាកនឹងអូសទាញមក ប៉ុន្តែខ្ញុំព្យាយាមរហូត។

ក៖ ចាស។

ខ៖ ប្ដីខ្ញុំគាត់ព្យាយាមអូសទាញគាត់ហា ។

ក៖ ចាសបង។

ខ៖ បងខ្ញុំពីនាក់ហា ចូលព្រះវិហារហា។

ក៖ ចាសបង។

ខ៖ ប៉ុន្តែដោយសារមួយទៀតគាត់ទៅនៅស្រុកហា។

ក៖ ចាស។

ខ៖ កាលហ្នឹងគាត់អើ មកធ្វើការនៅភ្នំពេញហ្នឹង គាត់នៅផ្ទះជួលអញ្ចឹង គាត់បានចូលទៅព្រះវិហារទៅអីអញ្ចឹង ដំពេលគាត់អស់ការងាទៅគាត់ទៅស្រុក។

ក៖ ចាសបង។

ខ៖ ចាសទៅស្រុក។

ក៖ ចុះអើ ម្ដាយរបស់បងឈ្មោះអីគេដែរ?

ខ៖ គាត់ឈ្មោះ នៅ មៃ។

ក៖ នៅ មៃ?

ខ៖ ចាស។

ក៖ ចាស ហើយចុះឪពុក?

ខ៖ ឪពុកខ្ញុំឈ្មោះអើ ចឹក គ្រឿន។

ក៖ ចឹក គ្រឿន?

ខ៖ ចាស។

ក៖ ចាសបង ចុះពួកគាត់ទាំងពីរបើគិតមកដល់ឥឡូវគាត់មានអាយុមាណអស់ហើយ?

ខ៖ ហ្អឺរ អាយុប៉ាខ្ញុំប្រហែលជា ប៉ែតជាងជិតកៅហើយដឹងខ្ញុំអត់សូវនេះដែរហ្នឹងហា។

ក៖ ចុះម៉ាក់?

ខ៖ ម៉ាក់ខ្ញុំដូចជាប៉ែត ប៉ែតបួន។

ក៖ ប៉ែតបួន?

ខ៖ ចាស។

ក៖ ហ្អឺរ អាយុច្រើនៗហើយ?

ខ៖ ចាស គាត់នៅ ប៉ុន្តែប៉ាខ្ញុំគាត់ស្លាប់ហើយ។

ក៖ ហ្អឺរ តែម៉ាក់នៅ?

ខ៖ ចាស នៅ។

ក៖ ហ្អឺរ ចុះបងចាំថាគាត់ទាំងពីកើតនៅថ្ងៃណា? ខែណា? ឆ្នាំណាហ្អេ?

ខ៖ ខ្ញុំអត់ចាំផង គាត់អត់ដែរនិយាយសោះ។

ក៖ ហិហិហិ។

ខ៖ ហើយណាមួយគាត់អត់ចាំទេ ចាស់ៗនៅជនបទគាត់អត់ចាំខ្លួនឯងផងហ្នឹង។

ក៖ ចុះគាត់?

ខ៖ តាខ្ញុំអីគាត់អត់ចាំខ្ញុំដែរហ្នឹង គាត់គ្រាន់តែដឹងថាកើតកត្តិក។

ក៖ ហ្នឹងហើយ។

ខ៖ ហើយឆ្នាំ។

ក៖ នាក់ខ្លះទៀតអើ។

ខ៖ តែប៉ុណ្ណឹងហ្អេ គាត់ចាំតែប៉ុណ្ណឹងហ្អេ។

ក៖ ខែស្លឹកអំពិលលាស់ ហិហិហិហិ។

ខ៖ ចាស គាត់ចាំថាខ្ញុំកើតពេលខែកត្តិក។

ក៖ ចាសបង។

ខ៖ ខែកត្តិក ហើយអើ ឆ្នាំមមី។

ក៖ ចាស។

ខ៖ តែប៉ុណ្ណឹង គាត់ចាំតែប៉ុណ្ណឹងហ្អេ។

ក៖ ចាសចាស ចុះបងចាំថ្ងៃខែ ដូចជាឆ្នាំខ្មែរគាត់ហ្អេ? ដូចជាឆ្នាំសត្វអីហា?

ខ៖ ម៉ែខ្ញុំ សត្វមើលសត្វ ដូចជា ដូចសត្វជ្រូក។

ក៖ សត្វជ្រូកឆ្នាំកុរ?

ខ៖ ហ្នឹងហើយ ប្រហែលជាកុរហ្នឹង។

ក៖ ចុះឪពុក?

ខ៖ ឪពុកខ្ញុំ អើ ឆ្នាំចរ។

ក៖ ចរ ឆ្កែរ?

ខ៖ ហ្នឹងហើយ។

ក៖ ចាស ចុះបងដឹងថាពួកគាត់កើតនៅ? ទីកន្លែងគាត់នៅណាហ្អេ? ដូចជានៅភូមិអី?

ខ៖ គាត់នៅអើ ខាងអើ ខេត្តកណ្ដាលអើ ស្រុកស្អាងដូចខ្ញុំដែរ។

ក៖ អញ្ចឹងបង?

ខ៖ ឪពុកខ្ញុំ។ ហើយបើម៉ែខ្ញុំគាត់កើតនៅអើ ស្រុកហ្នឹងជាមួយគ្នារប៉ុន្តែគ្រាន់តែភូមិខុសគ្នារ។

ក៖ នៅភូមិអីគេបង?

ខ៖ ចាស ម៉ាក់ខ្ញុំគាត់នៅអើ ខាងភូមិព្រែកទទឹង។

ក៖ ព្រែកទទឹង?

ខ៖ ចាស ព្រែកទទឹង។

ក៖ តែនាក់ខេត្តកណ្ដាល?

ខ៖ ខេត្តកណ្ដាលដែរ។

ក៖ ចាសបង។

ខ៖ ស្រុកស្អាងអីជាមួយគ្នារដែរ។

ក៖ ចាស។

ខ៖ តែខុសភូមិហា។

ក៖ ចាសបង។

ខ៖ ចាស។

ក៖ ចាស អើ តើឪពុករបស់បងគាត់បានប្រកបមុខរបរអីខ្លះដើម្បីចញ្ចឹមជីវិតគាត់ដែរ?

ខ៖ កាលអើ ពីខ្ញុំនៅតូចហា គាត់អើ ជានាក់រកស៊ីគោ។

ក៖ ហ្អេរ ជួញគោ?

ខ៖ ចាស គាត់ជានាក់ជួញគោហា។

កៈ ចាស។

ខៈ ចាស ហើយម៉ាក់ខ្ញុំគាត់ធ្វើស្រែធ្វើចំការអញ្ចឹងទៅណា។

កៈ ចាស។

ខៈ មើលថៃកូនចៅអញ្ចឹងទៅណា។

កៈ ចាស ហើយចុះឪពុករបស់គាត់ជាមនុស្សរបៀបណា? ដូចជាមនុស្សកាចឬក៏ស្លូត?

ខៈ គាត់ជាមនុស្សស្លូតហ្អេ។

កៈ ហ្អរ ចាសចាស។

ខៈ ចាស គាត់អត់កាចទេ។

កៈ ចាសចាស ចុះម្ដាយរបស់បងគាត់ប្រកបមុខរបរអីដើម្បីចញ្ចឹមជីវិតគាត់?

ខៈ គាត់ធ្វើស្រែធ្វើចំការ។

កៈ ហ្អរ?

ខៈ ហើយមើលថៃកូនតែប៉ុណ្ណឹង។

កៈ ចាស។

ខៈ គាត់នៅស្រុកស្រែ។

កៈ ចាស ចុះគាត់ជាមនុស្សបែបណាដែរ? កាចឬក៏ស្លូត?

ខៈ គាត់ជាមនុស្សស្លូត។

កៈ ស្លូតទាំងពីនាក់?

ខៈ ចាសចាស ស្លូតទាំងអស់ម៉ែខ្ញុំប៉ាខ្ញុំ។

កៈ ហ្អរ។

ខ៖ គាត់ស្លូតៗណាស់។

ក៖ ចាសបងចាស ហើយចុះសំរាប់បង តើបងចងចាំអើ រឿងអីខ្លះដែរបងបានមានជាមួយហ្នឹង ឪពុកម្ដាយបងហ្អេស? ដូចជាមានអនុស្សាវរីយ៍ជាមួយពួកគាត់ហា? ដូចចូលចិត្តទៅណាខ្លះ? ដូចចូលចិត្តធ្វើអីខ្លះជាមួយគាត់?

ខ៖ ខ្ញុំជាមួយគាត់អើ កាលពីតូចខ្ញុំធ្លាប់ទៅជាមួយឪពុកខ្ញុំហា។

ក៖ ចាស។

ខ៖ ខ្ញុំទៅកាប់អូស។

ក៖ ហ្អរ។

ខ៖ ទៅកាប់អូសជិះទូកទៅឆ្ងាយៗហា។

ក៖ ចាស។

ខ៖ ចាស ឡើងពីយប់ៗទៅ កាប់អូសជាមួយគាត់ទៅ ហើយខ្ញុំនៅក្មេងហា ខ្ញុំចូលចិត្តលេង លេងអាររៀបតាមទូកតាមទឹកហ្នឹងខ្ញុំចូលចិត្តទៅហា ទៅតាមគាត់។

ក៖ ហិហិ។

ខ៖ ហ្នឹងហើយ។

ក៖ ចូលចិត្តជិះទូកជិះអី?

ខ៖ ចាស ទៅចាសទៅហើយដូចថាកាប់អូសកាប់អីជាមួយគាត់ទៅមានភាពសប្បាយអីអញ្ចឹងហា នៅក្មេងហា។

ក៖ ចាស។

ខ៖ ចង់តែលេងអញ្ចឹងហ្អែ។

ក៖ ចាស។

ខ៖ ចាស។ ហើយបើជាមួយម៉ាក់ខ្ញុំវិញអើ ទូលថ្នាំដើរលក់អញ្ចឹង ខ្ញុំចង់ដើរតាមគាត់អញ្ចឹងទៅ បានឆ្ងាយៗស្គាល់តាមនេះ។

ក៖ តាមភូមិ?

ខ៖ តាមភូមិតាមអីអញ្ចឹងហា។

ក៖ ចាស។

ខ៖ ចាស បានស្គាល់បានអីអញ្ចឹងទៅទូលថ្នាំជក់លក់ហ្អេរ។

ក៖ ចាស។

ខ៖ ជំនាន់ហ្នឹងគេធ្វើថ្នាំហា។

ក៖ ចាសចាស។

ខ៖ ចាស។

ក៖ ចុះអើ ពួកគាត់ទាំងពីធ្លាប់ប្រាប់អ្វីខ្លះទៅកាន់បង នៅពេលដែរពួកគាត់នៅក្មេងៗហ្អេ?

ខ៖ ចាស។

ក៖ ដូចជាគាត់ធ្លាប់បានប្រាប់បងថា ជីវិតរបស់ឪពុកម្ដាយបងនៅក្មេងៗគាត់ធ្លាប់បានឆ្លងកាត់អីមកខ្លះបងធ្លាប់?

ខ៖ គាត់ធ្លាប់និយាយរឿងពលពត សម័យពលពតហា គាត់គិតថាចេះអើ ចេះតែដាស់តឿនកូនហា។

ក៖ ចាស។

ខ៖ អោយពេលប្រលឹមឡើងទៅ យើងងើបពីព្រឹកៗទៅដើម្បីជួយធ្វើការងាផ្ទះគាត់ហា។

ក៖ ចាស។

ខ៖ ការងាចំការ កាងារអីអញ្ចឹងហា។

កៈ ចាស។

ខៈ អញ្ចឹងគាត់ចេះតែថា បើកូនឯងដេកអញ្ចឹង ជំនាន់ពលពតគេវៃងាប់អស់ហើយ ទាល់តែកូនឯងងើបពីព្រឹកៗ។

កៈ ចាស ហិហិ។

ខៈ បាន បាននេះទៅ ហើយអើ ស្រុកឥឡូវហ្នឹង ក៏គេនេះដូចថាវាខ្យាណប្រាណវា វាអត់មានសង្គ្រាមមានអីអញ្ចឹងហា។

កៈ ចាស។

ខៈ ដំយើងខំប្រឹងទៅ បានយើងមានលុយកាក់អើ ដើម្បីអើ ចាយវាយក្នុងក្រុមគ្រួសារហា អញ្ចឹងគាត់ចេះតែអោយយើងសហាការជាមួយគាត់ហា ដើម្បីជួយគាត់ហា។

កៈ ចាសបងចាស។

ខៈ ចាស។

កៈ ចាស អញ្ចឹងគាត់រំលឹកយើងច្រើន?

ខៈ ចាស រំលឹក។

កៈ ចាសបង ហើយតើបងចងចាំឈ្មោះរបស់ជីដូនជីតារបស់បងទាំងខាងម្តាយនឹងខាងឪពុកហ្អេស?

ខៈ ខ្ញុំអើ ចាំតែយាយចុងខាងម៉ាក់ខ្ញុំទេ អើ យាយបង្កើតអើ យាយបង្កើតហ្នឹងដូចជាខ្ញុំអត់សូវចាំទេ។

កៈ ហ្អរ?

ខៈ គាត់ដូចអត់ ដូចខ្ញុំចន្លោះហ្នឹងខ្ញុំអត់បានសួរគាត់ ។

កៈ ចាស។

ខៈ ដូចជា មិនដឹងថាខ្ញុំសួរគាត់ពីមុនមកខ្ញុំភ្លេចមិនដឹងទេណា។

កៈ ចាសបង។

ខៈ ខ្ញុំចាំតែយាយចុងគាត់អើ គាត់ឈ្មោះយាយ ខាត់។

កៈ យាយ ខាត់?

ខៈ ហើយតាខ្ញុំហ្នឹង គាត់ឈ្មោះតា នៅ។

កៈ តា នៅ?

ខៈ ចាស។

កៈ ចុះខាងឪពុក?

ខៈ ខាងឪពុកខ្ញុំចាំតែអើ នេះហ្អេ តាដែរហ្នឹង។

កៈ ចាស។

ខៈ ចាំជីតាអើ ឈ្មោះអើ តាចឹក។

កៈ តា ចឹក?

ខៈ ហើយដំពេលយាយហ្នឹងខ្ញុំអត់ចាំហា។

កៈ ចាសបងចាស។

ខៈ ចាស ដោយសារគាត់ស្លាប់ចោលគាត់ហ្នឹងយូពេក ហើយខ្ញុំអត់បានសួរគាត់ហា។

កៈ យើងកើតអត់ទាន់។

ខៈ ចាស កើតអត់ទាន់ទេ ហើយដល់តែពេលយើងរៀងធំៗទៅអត់មាននាក់ណាគេស្និតស្នាលទៅខាងហ្នឹងហ្អរ។

កៈ ហ្អរ?

ខៈ ដូចថាអារបៀបយើងដើរមក។

កៈ ឆ្នាយ?

ខៈ ឆ្ងាយពីគ្នារ ចាស។

កៈ ចាសបង ហើយអើ តើបងចងចាំថ្ងៃខែឆ្នាំកំណើតរបស់ជីដូនជីតាបងទាំងសងខាងហ្អេស?

ខៈ ដូចអត់ចាំសោះ។

កៈ ចុះឆ្នាំខ្មែរ?

ខៈ ខ្មែរក៏អត់ចាំដែរ។

កៈ ចាស។

ខៈ ព្រោះដោយសារគាត់អើ យើងនៅតូចៗ យើងនៅជាមួយគាត់ហ្នឹង យើងអត់បានសួរគាត់ហា។

កៈ ចាស។

ខៈ ហើយដូចថាអើ គាត់ស្លាប់យូហើយទៅយើង ដូចថានៅក្មេងៗអញ្ចឹងដូចយើងអត់សួរយកចិត្តទុកដាក់ដែរ។

កៈ ចាសបង។

ខៈ ចាស ដំតែធំហ្នឹងយើងអត់ ភ្លេចនៅក្នុងការសួរដែរហ្នឹងហា ដូចថាចាស់ៗគាត់ស្លាប់យូហើយ យើងលែងយកចិត្តទុកដាក់ហ្អរ។

កៈ ចាសបងចាស។

ខៈ ចាស។

កៈ ហិហិ ចុះបងធ្លាប់ដឹងរឿងអីខ្លះអំពីជីវិតរបស់ជីដូនជីតាបងហ្អេស?

ខៈ ធ្លាប់ដឹងជីតាខ្ញុំហា គាត់អើ នៅក្មេងៗគាត់ស្រឡាញ់ចៅហា។

កៈ ហ្អរ?

ខ៖ ដ៏ហើយយាយចុងនេះក៏អញ្ចឹងដែរ ខ្ញុំឧស្សាហ៍ទៅលេង ណាជិះទូក អើ ផ្ទះខ្ញុំហើយផ្ទះគាត់ឆ្លងទូក។

ក៖ ចាស។

ខ៖ ឆ្លងទូកហ្នឹងមានទន្លេហា។

ក៖ ចាស។

ខ៖ ឆ្លងហើយ ខ្ញុំទៅអើ ជំនាន់ហ្នឹងអត់មានកង់ជិះហ្អេ។

ក៖ ចាស។

ខ៖ ខ្ញុំដើរហា ដើរឆ្ងាយហាណា។

ក៖ ហ្អេរ?

ខ៖ ឆ្ងាយហា ដើរប្រហែលជាដើរអើ ពីព្រឹករហូតទៅដល់ម៉ោង១១។

ក៖ ហ្អេរ?

ខ៖ បានដល់ផ្ទះគាត់។

ក៖ ចាស។

ខ៖ ហើយខ្ញុំចូលចិត្តដើរទៅ ហើយខ្ញុំជិះទូកទៅទៅ ខ្ញុំទៅគាត់ហ្នឹង ទៅលេងហើយផ្ទះគាត់ហ្នឹងមានកូស្គរកូអញ្ចឹងទៅ ខ្ញុំអើ ចូលចិត្តទៅលិតអាស្គរ អាឆ្នាំងខ្ទះគាត់ហ្អេរ។

ក៖ ហិហិ ស្គរតាំង ស្គរ។

ខ៖ ហ្នឹងហើយអើ យកអា អាធាងត្នោតហ្នឹងកិលលិតអញ្ចឹងទៅ។

ក៖ ហ្អេរ?

ខ៖ ហើយវាឆ្ងាញ់ណាស់ជំនាន់ហ្នឹងដូចថា។

ក៖ ស្គរ គេហៅស្គរតាំងអី?

ខ៖ ស្ករត្នោត។

ក៖ ស្ករត្នោត?

ខ៖ ហ្នឹងហើយ គេកូស្ករត្នោត គេយកទឹកត្នោតមកចាក់ហ្អរ។

ក៖ ហ្អរ?

ខ៖ ចាក់ដាក់ខ្វះហើយ គេកូរឹកកូរឹកទៅដើម្បីអោយ ដំពេលគេដូសអាស្ករហ្នឹងនៅជាប់អាបាត ឆ្នាំងខ្វះហ្នឹង ឆ្ងាញ់ហាណា។

ក៖ ឆ្អឹសញាំ?

ខ៖ ចាស នៅជំនាន់តូច។

ក៖ ហ្អរ?

ខ៖ តូចៗហ្នឹងខ្ញុំចូលចិត្តណាស់។

ក៖ ចាសបង។

ខ៖ ដូចថាគាត់នេះអញ្ចឹងគាត់ចាស់ៗ គាត់ចូលចិត្តធ្វើអើ គ្រឿងបុរាណហា។

ក៖ ចាស។

ខ៖ គាត់ឆ្នៃយកអា អាត្រលោកដូងហ្នឹងហាធ្វើជាវែក ហើយខ្ញុំចូលចិត្តខ្ញុំស្រឡាញ់ហា ខ្ញុំចូលចិត្តរបស់គាត់ហា។

ក៖ ឥឡូវរកទិញអត់មានទេ។

ខ៖ អត់មានទេ។

ក៖ ហិហិហិ។

ខ៖ ហើយគាត់ស្លាប់បាត់ហើយ គាត់ធ្វើជាវែកសម្លរ វែកបាយ គឺអាវែកដាក់អើ ត្រលោកដូងហ្នឹងហា។

កៈ ចាស។

ខៈ គាត់ឆ្នៃបានច្រើនហា គាត់ធ្វើបានច្រើនមែនទែន។

កៈ ចាស។

ខៈ ចាស។

កៈ ចាសបងចាស មាន?

ខៈ ហើយខ្ញុំចូលចិត្តទៅគាត់ហា ទៅអញ្ចឹងទៅដំពេលមកផ្ទះវិញហា ចុះនៅក្មេងៗហ្អេរ អត់ដឹងអីទេ គាត់អោយលុយមកសប្បាយអរហា។

កៈ ហិហិហិ។

ខៈ ថាតាហ្នឹងហើយចិត្តល្អស្រឡាញ់ចៅហ្អេរ។

កៈ ចាស។

ខៈ រួចយាយក៏អញ្ចឹងដែរ យាយចុងហ្នឹងក៏គាត់ចិត្តល្អអញ្ចឹងដែរ។

កៈ ចាសចាស។

ខៈ ចាស គាត់ស្រឡាញ់ចៅៗ។

កៈ បងមានអនុស្សាវរីយ៍ជាមួយគាត់ ច្រើន។

ខៈ ហិហិ ជាមួយគាត់ច្រើន។

កៈ ចាស ចុះអើ?

ខៈ បើខាងឪពុកខ្ញុំអត់សូវមានទេ ព្រោះខ្ញុំអត់ទាន់គាត់។

កៈ ហ្អេរ?

ខៈ អត់ទាន់គាត់ យើងទាន់តែអ៊ុំៗ អើអ៊ុំហ្អេ។

កៈ ចាសចាស ហើយចុះអើ ក្រុមគ្រួសារបងមករស់នៅទីក្រុងភ្នំពេញអស់រយៈពេលមាណឆ្នាំហើយ?

ខៈ អត់មាននាក់មកទេ មានតែខ្ញុំទេ ម៉ាក់ខ្ញុំអីគេនៅស្រែទាំងអស់។

កៈ អញ្ចឹងបងមកនៅភ្នំពេញមាណឆ្នាំហើយ?

ខៈ បងមកនៅភ្នំពេញតាំងពីអាយុ១៧ហ្អរ ចេញពីគាត់ហ្អរ ខ្ញុំចេញពីគាត់ហ្នឹង មិនមែនថាខ្ញុំមកធ្វើអីទេ ខ្ញុំមកស៊ីឈ្នួលគេហា។

កៈ ហ្អរ?

ខៈ ស៊ីឈ្នួលគេដូចថា គេអោយធ្វើអីក៏ធ្វើដែរអោយតែថាខ្ញុំបានលុយយកទៅជួយដល់ក្រុមគ្រួសារខ្ញុំ ដើម្បីអោយក្រុមគ្រួសារខ្ញុំរីកចំរើនឡើង កុំអោយថាអើ ទាំងអស់គ្នារនៅស្រែអញ្ចឹងហា ដូចថាអត់មានដឹងថាធ្វើអីធ្វើតែស្រែអត់មាននាក់ណាលោតអីឡើងជួយនាក់ណាបានហា។

កៈ ចាស។

ខៈ ចាស អញ្ចឹងខ្ញុំម្នាក់ឯងហ្នឹង ខ្ញុំខំតស៊ូហា ខ្ញុំគិតក្នុងចិត្តមួយថាខ្ញុំនឹងងើបម្នាក់ឯងឡើងទាល់តែរួចដើម្បីជ្រោងក្រុមគ្រួសារអោយធូធាឡើង។ព្រោះក្រុមគ្រួសារខ្ញុំអត់ណាស់។

កៈ ចាស។

ខៈ ខ្ញុំតែសូម្បីតែកង់អត់មានជិះផង ជំនាន់ហ្នឹង។

កៈ ចាស។

ខៈ ហើយខ្ចីកង់បងហា ក៏គាត់អត់អោយដែរណា យើងទៅណាស្មើរជើងទាំងអស់។

កៈ ហ្អឺ ដ៏ពេលអញ្ចឹងបងតស៊ូ?

ខៈ បងយើងចិត្តល្អ ហ្នឹងហើយខ្ញុំតស៊ូ ខ្ញុំនឹកឃើញអាភាពថា ចង់ជិះកង់គាត់ គាត់អត់អោយអញ្ចឹងទៅដូចថា តែបើនាក់ដ៏ទៃគាត់អោយ។

កៈ ហ្អឺ។

ខៈ អញ្ចឹងហា។

កៈ ពិបាកអញ្ចឹងហា ហិហិហិ។

ខៈ ចាស ដ៏អញ្ចឹងខ្ញុំចេះតែនឹកឃើញថាអើ ខ្ញុំខំមកស៊ីឈ្នួលគេ ប្រាក់ខែជំនាន់ហ្នឹងតែសាមប្រាំហ្អេ។

កៈ ចាស។

ខៈ ក្នុងមួយខែ។

កៈ ចាស។

ខៈ អញ្ចឹងខ្ញុំស៊ីឈ្នួលគេ ដំបូងខ្ញុំមើលកូនបងប្អូនអោយ ដ៏ខ្ញុំមើលយូៗទៅ ខ្ញុំមានបងធម៌ម្នាក់ហ្នឹងគាត់បានប្តីជនជាតិបរទេសទៅគាត់យកខ្ញុំទៅនៅជាមួយទៅ។

កៈ ហ្អរ?

ខៈ ទៅនៅជាមួយខ្ញុំចេះៗតែនឹកឃើញថា គេផ្តល់កំលាំងចិត្តយើងដើម្បីមានភាពអោយរឹងមាំដែរហា។

កៈ ចាស។

ខៈ ចាស គេជួយយើងដែរ។

កៈ ចាស។

ខៈ យើងគេស្រឡាញ់យើង រាប់អានយើង ដ៏ខ្ញុំបានគាត់ហ្នឹងហា បានបាននៅភ្នំពេញឈរជើងជាប់ហ្នឹងហា ហើយដ៏យើងគិតថាមិនដឹងធ្វើអី យើងមិនដឹងទៅខាងណា យើងមានបងប្អូនដូចថាបងប្អូនអីយើងគិតតែរៀងខ្លួនអញ្ចឹងទៅណា ហើយសាច់ឆ្ងាយទៀតហើយយើងអត់មានបងប្អូននៅភ្នំពេញហ្អេ។

កៈ ចាស។

ខ៖ មានតែម្នាក់ហ្នឹងគេភ្នំពេញហ្នឹង ដែរខ្ញុំមកនៅដំបូងគេហ្នឹង។

ក៖ ចាស។

ខ៖ ហើយខ្ញុំស្គាល់ម្នាក់ទៀតទៅ បានបានខ្ញុំនៅតតតៗទៀតមក។

ក៖ ហ្អេរ រហូតដល់សព្វថ្ងៃ?

ខ៖ ចាស សព្វថ្ងៃ។

ក៖ ហើយចុះបងមានសាច់ញាតិណាដែររស់នៅក្រៅប្រទេសខុសពីស្រុកខ្មែរហ្អេស?

ខ៖ មានខាងឪខ្ញុំ ក្មួយគាត់។

ក៖ ហ្អេរ គាត់រស់នៅប្រទេសណាបង?

ខ៖ ខ្ញុំអត់ដឹងថា ដឹងតែថានៅអាមេរិក ប៉ុន្តែអត់ដឹងនៅរដ្ឋអីទេខ្ញុំអត់ដឹងទេ។

ក៖ គាត់ឈ្មោះអីគេដែរ?

ខ៖ គាត់ឈ្មោះ សៀន។

ក៖ ឈ្មោះ សៀន?

ខ៖ ចាស ឈ្មោះ សៀន។

ក៖ បងដែរទាក់ទងគាត់ហ្អេស?

ខ៖ ពីមុនខ្ញុំធ្លាប់ទាក់ទងគាត់ តែឥឡូវហ្នឹងដាច់ទៅ ដូចថាគេផ្តាច់អត់សូវទំនាក់ទំនងហា បងប្អូនទាំងអស់គាត់អត់សូវទំនាក់ទំនងទាំងអស់។

ក៖ ដំពេលអញ្ចឹង អត់មាន?

ខ៖ ចាស អញ្ចឹងលែងសូវមានការទំនាក់ទំនងគ្នារហើយ។

ក៖ ចាសបងចាស ចុះស្វាមីបងឈ្មោះអីគេដែរ?

ខ៖ ស៊ុយ ឆៃលាង។

ក៖ ស៊ុយ ឆៃលាង?

ខ៖ ចាស។

ក៖ ចាស ហើយអើ បងរៀបអាពាហ៍ពិពាហ៍នៅថ្ងៃណា? ខែណា? ឆ្នាំណាដែរ?

ខ៖ ខ្ញុំអើ ឆ្នាំ២០០០។

ក៖ ឆ្នាំ២០០០? ថ្ងៃ?

ខ៖ អើ ដូចជាថ្ងៃ២៥ហើ? ឆាប់ភ្លេចហា។

ក៖ ហិហិ ចាំឆ្នាំអញ្ចឹង?

ខ៖ ចាំឆ្នាំ។

ក៖ ចាសបង ចុះអើ ការរៀបអាពាហ៍ពិពាហ៍ហ្នឹង ត្រូវបានរៀបចំឡើងដោយឪពុកម្ដាយបង ឬក៏បងរៀបចំវាឡើងដោយខ្លួនឯង?

ខ៖ តាមពិតអើ ខ្ញុំរៀបចំដោយខ្លួនឯងហ្អេស ដោយខ្ញុំឃើញគ្នារទៅ ហើយប្ដីខ្ញុំគាត់ស្រឡាញ់គ្នារដែរទៅ អើ មិនមែនថានេះម៉ែឪរៀបចំទុកដាក់អោយដែរ ប៉ុន្តែអើ គាត់ស្គាល់ ស្គាល់ដោយសារយើងស្គាល់គ្នារដែរហា។

ក៖ ចាស។

ខ៖ ចាស យើងស្គាល់គ្នារតាមរយះមកព្រះវិហារហា។

ក៖ ហ្អរ?

ខ៖ ចាស ដ៏អញ្ចឹងខ្ញុំការនៅក្នុងព្រះវិហារថ្ងៃសៅរ៍។

ក៖ ហ្អរ?

ខ៖ ហើយតាមប្រពៃណីខ្មែរថ្ងៃអាទិត្យ។

កៈ ហ្អេរ ចាសបងចាស ហើយចុះអើ ពេលដែរបងរៀបអាពាហ៍ពិពាហ៍ហ្នឹង តើបងមានទទូល បានថ្លៃជំនូនហ្អេស? ដែរគេហៅថាថ្លៃទឹកដោះហា?

ខៈ មានថ្លៃទឹកដោះ ពីជំនាន់ហ្នឹង៥០០ទេ នៅតាមជនបទហ្នឹង៥០០ច្រើនហាណា។

កៈ ច្រើន។

ខៈ ចាស គេនៅស្រុកហ្នឹងគេថាយើងបានច្រើនណាស់ ហើយការជំនាន់ហ្នឹង យើងការគ្រប់ ហើយយើងនេះទៀត ធ្វើសល់ទៀត។

កៈ ចំនេញ?

ខៈ ចាស យើងចំនេញទៀត។

កៈ ចាស បង។

ខៈ ចាស ព្រោះនៅជំនាន់ហ្នឹង ភ្នងតែ តែមាណម៊ីនហ្នឹង ប្រាំពីម៊ីនហ្នឹង។

កៈ ហិហិហិ។

ខៈ ជួលភ្នងការហ្អេរ។

កៈ ចាស។

ខៈ ចាស។

កៈ ចាសបងចាស អញ្ចឹងតើឥឡូវបងអាចប្រាប់ខ្ញុំបានហ្អេស? អំពីមូលហេតុដំបូងដែរបងបាន ជួបបងប្រុស?

ខៈ ចាស បាន។

កៈ តើជួបនៅកន្លែងណា? ហេតុអីចាប់ផ្ដើមស្រឡាញ់គ្នារ? ហើយទាក់ទងគ្នាររហូតដល់រៀប ការ?

ខៈ ចាស កាលពីដំបូងខ្ញុំជួបគាត់នៅក្នុងព្រះវិហារខ្ញុំអត់ទាន់ចាប់អារម្មណ៍គាត់ទេ។

ក៖ ហ្អេរ?

ខ៖ ខ្ញុំទៅលេងហ្អេ ប៉ុន្តែគាត់ គាត់ចាប់អារម្មណ៏ខ្ញុំ។

ក៖ ចាស។

ខ៖ ចាស ប៉ុន្តែខ្ញុំអត់ដឹងខ្លួនទេ។

ក៖ ចាស។

ខ៖ ទាល់តែខ្ញុំទៅព្រះវិហារយូៗទៅ គាត់លួចស្រឡាញ់ខ្ញុំ ប៉ុន្តែខ្ញុំអត់មានបំណងលើគាត់ហ្អេ។

ក៖ ចាស។

ខ៖ ខ្ញុំគិតថាអើ ខ្ញុំចង់បានទៅចេញស្រុកក្រៅ។

ក៖ ហ្អេរ។

ខ៖ ព្រោះខ្ញុំមានអើ អើ បងធម៍ហ្នឹងគាត់ទំនាក់ទំនងអោយគាត់ចង់អោយយកខ្ញុំចេញក្រៅ។

ក៖ ចាស។

ខ៖ ដ៏អញ្ចឹងខ្ញុំអត់មានអើ ជាមួយប្តីខ្ញុំអត់មានការទាក់ទងទេដំបូង។

ក៖ ចាស។

ខ៖ ដឹងតែថាប្តីខ្ញុំគាត់ស្រឡាញ់ខ្ញុំ ប៉ុន្តែខ្ញុំអត់ស្រឡាញ់គាត់ហ្អេ។

ក៖ ហិហិហិ ចាស។

ខ៖ តែដល់ពេលអើ គាត់អើ បងលាងគាត់ចេញទៅផ្សាយមីសិនទៅ។

ក៖ ចាសបង។

ខ៖ ខ្ញុំហ្នឹងក៏ចេញពីផ្ទះគេនៅទួលគោកហា ខ្ញុំធ្លាប់នៅផ្ទះគេនៅជិតទួលគោកហ្នឹង វានៅព្រះវិហារសាខាទីពីដែរ អញ្ចឹងខ្ញុំចេះតែបានមកហាណា។

ក៖ ចាស។

ខ៖ ដល់ពេលខ្ញុំចេញមកធ្វើការនៅកន្លែងអើ វិមានឯករាជ ពេទ្យចិនហ្អរ។

ក៖ ចាស បង។

ខ៖ កន្លែងលក់ការសែតស៊ីឌី ខ្ញុំមកធ្វើការហ្នឹង ខ្ញុំក៏ធ្វើការបានប្រហែលជាជិតបានមួយឆ្នាំ ជិតមួយឆ្នាំ។

ក៖ ចាស។

ខ៖ ក៏បងលាងគាត់មកពីផ្សាយមីសិនវិញ គាត់អើ គាត់ជិះម៉ូតូតាមផ្ទះឡូវហោ។

ក៖ ចាស។

ខ៖ ហើយខ្ញុំទៅផ្សារ។

ក៖ ចាស។

ខ៖ ខ្ញុំទៅផ្សារទៅ គាត់ ឃើញ។

ក៖ ស្រែកហៅ?

ខ៖ ឃើញនោះ ឃើញគ្នារ។

ក៖ ហ្អរ។

ខ៖ ឃើញគ្នារដោយចៃដន្យ ខ្ញុំចេះតែថាម្នាក់ហ្នឹងខ្ញុំស្គាល់នៅណាទេ ប៉ុន្តែខ្ញុំអត់ដឹងថានៅកន្លែងណាហេ តែខ្ញុំសង្ស័យថាធ្លាប់ឃើញគាត់។

ក៖ ចាស។

ខ៖ ហើយគាត់ហៅឈ្មោះខ្ញុំហើយគាត់ហៅខ្ញុំ។

ក៖ ចាស។

ខ៖ ហើយខ្ញុំចេះតែរកនឹកហើយ រកនឹក ដ៏គាត់ប្រាប់ទៅបានថាហ្អរ?

កៈ នឹកឃើញហា?

ខៈ ហ្នឹងហើយ ព្រោះគាត់ ខ្ញុំស្គាល់គាត់នៅស្គម។

កៈ ហ្អរ?

ខៈ កាលគាត់នៅ នៅព្រះវិហារហោ គាត់ស្គមមែនទែន។ ហើយដំគាត់ទៅផ្សាយមីសិនហ្នឹង។

កៈ មកវិញធាត់?

ខៈ មកវិញធាត់ខ្ញុំមើលអត់ស្គាល់ហ្អេស។

កៈ ហិហិ ចាសបង ហើយក៏ចាប់ផ្តើមទាក់ទងគ្នារ?

ខៈ ចាស ក៏ចាប់ផ្តើមទាក់ទងគ្នារទៅ ក៏មានចិត្តហាណា។

កៈ ចាសបង។

ខៈ ចាស។

កៈ យូៗទៅ?

ខៈ ចាស។

កៈ រៀបការ?

ខៈ រៀបការ ហិហិ។

កៈ មានកូន។

ខៈ គាត់ៗអើ គាត់ទៅអើ គាត់ហានណាស់ខ្ញុំសរសើរគាត់ គាត់អើស្រឡាញ់ខ្ញុំហា គាត់ហានទៅដល់ម៉ែរខ្ញុំហា អើ គាត់ជិះម៉ូតូទៅហា គាត់អើ សុំបងជីដូនមួយខ្ញុំ ជីទូតមួយខ្ញុំហ្នឹងហា។

កៈ ចាស។

ខៈ អោយជូនទៅម៉ែខ្ញុំ។

ក៖ ហ្អេ?

ខ៖ ទៅគាត់ជិះម៉ូតូទៅតែគាត់ ហើយនឹងបងជីដូនមួយខ្ញុំមួយហ្អេស គាត់ហានទៅដល់ខាងខ្ញុំហា។

ក៖ ហ្អេ?

ខ៖ គាត់អត់មានម៉ែគាត់ទាំងអស់ គាត់អត់មានម៉ែគាត់មក មកជួយស្ដីដណ្ដឹងទេ គាត់ទៅដោយខ្លួនឯង។

ក៖ ចាស។

ខ៖ ចាស ខ្ញុំសរសើរគាត់ គាត់ខ្លាហាន។

ក៖ ចាសចាស។

ខ៖ ចាស។

ក៖ ហើយរហូតឥឡូវបងមានកូនហើយ ហិហិហិ។

ខ៖ ឥឡូវមានកូនហើយ បានបី ចំណាងដៃបានកូនបីហើយ។

ក៖ ជោកជ័យ ហិហិហិ។

ខ៖ ហិ ហ្នឹងហើយ។

ក៖ ចុះបងអើ ចេះអាននិយាយនឹងសរសេរភាសារខ្មែរបានល្អប៉ុនណាដែរ?

ខ៖ ខ្ញុំបានតិចបំផុតអាន។

ក៖ ហ្អេ?

ខ៖ ដំតែខ្ញុំប្រកប។

ក៖ ហ្អេ?

ខ៖ នៅ ចាស ប៉ុនណ្ហឹងៗ។

ក៖ ចាស។

ខ៖ ខ្ញុំមកព្រះវិហារ ដូចជាអានចម្រៀងអី ចម្រៀងដូចជាយើងចូលព្រះវិហារយូហើយ យើងចេះតែថា។

ក៖ ចំណាំ?

ខ៖ ចំណាំបទចម្រៀងហា ប៉ុន្តែយើងអក្សរយើងមើលចេះខ្លះអញ្ចឹងទៅណា។

ក៖ ចាស។

ខ៖ យើងមិនមែនដូចថាអត់សោះទេ ដូចថា។

ក៖ ចាស តែនិយាយបានល្អ?

ខ៖ ចាស។

ក៖ ចាស។

ខ៖ អើ ពេលសរសេរខ្ញុំសរសេរអត់សូវ។

ក៖ អត់សូវបានដែរ?

ខ៖ អត់សូវបាន ហ្នឹងហើយ។

ក៖ ចាសចាស។

ខ៖ ហ្នឹង ប៉ុណ្ណឹង។

ក៖ ចុះបងចេះភាសារណាផ្សេងខុសពីខ្មែរហ្អេស?

ខ៖ អត់ទេ។

ក៖ ចេះតែភាសារខ្មែរ?

ខ៖ អង់គ្លេស កាលពីមុនរៀនជាមួយបងលាង ចេះដែរ ប៉ុន្តែវាចេះមិនបានច្រើនហា ដំពេលយើងបោះបង់ទៅក៏ភ្លេចអស់។

កៈ ចាសបង។

ខៈ ចាស ជំនាន់ចូលរៀនព្រះវិហារដំបូងហ្អេរ។

កៈ ចាស ចុះបងអើ រៀនបានត្រឹមថ្នាក់ទីមាណដែរ?

ខៈ បានថ្នាក់ទីបួន។

កៈ ទីបួន? បងរៀននៅសាលាណា?

ខៈ រៀននៅអើ កោះខែល នៅខេត្តកណ្ដាលហា នៅស្អាងហា។

កៈ ហ្អេរ ចា។

ខៈ ចាស ជំនាន់ហ្នឹងទៅរៀនដើរហ្នឹង ទំរាំតែដើរដល់ផ្ទះដល់សាលានៅតូចៗហ្អេរ។

កៈ ពីបីម៉ោង ហិហិហិ?

ខៈ ពីបីម៉ោង ហិហិ ដើរបណ្ដើនៅមើលតាមស្ពានហ្នឹង។

កៈ ទេសភាព?

ខៈ មើលអីហ្នឹង ហ្នឹងហើយ មកវិញហ្នឹងមើលតែដង្កូវ ព្រោះខ្លាចដង្កូវនៅអាកន្លែងមាន អាកន្លែងស្ពានឈើមួយហ្នឹងហា ដើរតាមហ្នឹងសុទ្ធតែដង្កូវ។

កៈ ហ្អេរ?

ខៈ ហើយដង្កូវហ្នឹងធំៗហា ប៉ុនៗមេជើងហើយភ្នែកវាក្រលោតៗហើយខ្ញុំ ទំរាំដល់ផ្ទះមកមើលតែកន្លែងហ្នឹងហ្អេ។

កៈ ហិហិហិ។

ខៈ មួយដើមហ្នឹងសុទ្ធតែដង្កូវ។

កៈ ចាស។

ខៈ ហ្នឹងហើយ នៅក្មេងៗ។

កះ ចាស បង មានបទពិសោធន៍ច្រើន?

ខះ ច្រើន។

កះ ចាស ហើយចុះបងតាំងពីក្មេងមកបងធ្លាប់មានមិត្តភក្រ័ណាដែរស្និតស្នាលហើយបានធំធាត់ឡើងមកជាមួយគ្នារហ្អេស?

ខះ ខ្ញុំមានមិត្តភក្រ័ ខ្ញុំមិត្តភក្រ័វាមានច្រើនដែរណា ប៉ុន្តែដូចថាយើងអើ ចាប់ជាដៃគូចូលចិត្តគាត់ គាត់នាក់ល្អអីអញ្ចឹងហា។

កះ ចាសបង។

ខះ តែម្នាក់ហ្អេស មិត្តភក្រ័ខ្ញុំ។

កះ ចាស។

ខះ ចាស គាត់ល្អណាស់។

កះ គាត់ឈ្មោះអី?

ខះ គាត់ឈ្មោះអើ អារ៉េន។

កះ អារ៉េន?

ខះ ចាស។

កះ រាល់ថ្ងៃបងនៅទាក់ទងគាត់ហ្អេស?

ខះ នៅទាក់ទងតើ គាត់អើ រាល់ថ្ងៃគាត់នៅលក់នៅតាខ្មៅ។

កះ ហ្អរ?

ខះ ចាស មិត្តភក្រ័ជិតស្និត ដូចថាតាំងពីតូចមក គាត់ឃើញយើងភាពក្រីក្រអីអញ្ចឹង ក៏គាត់អត់រើសអើងដែរ គាត់កូននាក់មានហា គាត់មានអីយកមកអោយខ្ញុំ ព្រោះអីផ្ទះខ្ញុំអត់អីញាំអញ្ចឹងហា គាត់យកពងទាមកអោយយើងហា ជំនាន់ហ្នឹងខ្ញុំបានតែពងទាក៏ខ្ញុំអរដែរ។

កៈ ចាសបង។

ខៈ ចាស ព្រោះខ្ញុំនៅតូចៗហា ពេលព្រឹកឡើងហូបបាយអត់ដៃរទាន់បងៗទេ ហូបបាយកក ហ្នឹង ជួនកាលមានកកជាមួយស្ករក៏ខ្ញុំហូប។

កៈ ចាស។

ខៈ ព្រោះឪខ្ញុំគាត់ចូលចិត្តស្ករ ចូលចិត្តស្វាយទុំអញ្ចឹងទៅណា។

កៈ ញាំជាមួយស្វាយទុំ?

ខៈ ចាស អញ្ចឹងហូប អើ ដូចថាអត់អីហូបអញ្ចឹងទៅ អោយតែបានបាយកកនៅគឺខ្ញុំយកមក ហូប ទិញទឹកត្នោតគេតា ជំនាន់ហ្នឹងមានតែមួយរៀលហ្អេ ចាយមួយរៀលហ្អេ។

កៈ ចាស។

ខៈ ទិញទឹកត្នោតគេមកហូប បានទឹកត្នោតផ្អែមហ្នឹងយកមកហូបជាមួយបាយកកអញ្ចឹងទៅ។

កៈ ហ្អឺ?

ខៈ អញ្ចឹងទៅ ចេកទុំ។

កៈ ចាស។

ខៈ ចាស នៅស្រែហា។

កៈ ចាស អញ្ចឹងបងមាន?

ខៈ ចុះបងប្អូនច្រើនហា។

កៈ បងមានបទពិសោធន៍ជាមួយមិត្តភក្រ័បងច្រើនដែរ?

ខៈ ច្រើន។

កៈ ជួយគ្នារ?

ខៈ ចាស ជួយគ្នារ អោយតែខ្ញុំអត់អីហូបគឺគាត់យករបស់ពីផ្ទះគាត់មកអោយហូបហើយ។

កៈ ហ្អរ ចាស។

ខៈ គាត់ចិត្តល្អហា។

កៈ ចាស។

ខៈ ចាស ដូចឃើញថាឃើញគំរូគាត់ធ្វើល្អអញ្ចឹង យើងចេះមកធ្វើគំរូតាមរហូតអញ្ចឹងទៅណា។

កៈ ចាសបង។

ខៈ ចាស។

កៈ ចុះបងអើ ធ្លាប់ធ្វើស្រែចំការឬក៏?

ខៈ ខ្ញុំធ្លាប់ធ្វើស្រែ ធ្វើស្រែ ខ្ញុំធ្វើៗខ្លាំងណាស់ស្រែ។

កៈ ហ្អរ ចាស។

ខៈ ថាគ្មាននាក់ណាស្ទូងទាន់ខ្ញុំហ្អេ ជ្រូតក៏មានណាគេជ្រូតទាន់ខ្ញុំដែរ។

កៈ ហិហិ។

ខៈ ហើយខ្ញុំដឹកស្រូវ។

កៈ ជំនាញ?

ខៈ ចាស ជំនាញមក រឿងស្រែជំនាញមង។

កៈ ចាសបង។

ខៈ បើថាការរៀនខ្ញុំខ្ជិល។

កៈ ហ្អរ។

ខៈ កាលហ្នឹងខ្ញុំខ្ជិលណាស់ ហើយម៉ែខ្ញុំគាត់ចេះតែដាស់តឿនថាចេះ កូនឯងខំរៀនទៅតែកូនឯងអត់ខំរៀនស្តាយក្រោយហើយ មែនដូចពាក្យគាត់ថាអញ្ចឹង។

កៈ ចាស។

ខៈ យើងគិតថាភាពអើ ក្រីក្រយើងឃើញម៉ែយើងឃើញពិបាកពេក ហើយយើងបងប្អូនប្រុសៗគេការអស់ទៅ អញ្ចឹងយើងគិតតែថាមិចជួយគាត់ដើម្បីកុំអោយគាត់ពិបាកហា។

កៈ ចាស។

ខៈ ហ្អេរ ខ្ញុំដឹកស្រូវហា ខ្ញុំស៊ីឈ្នួលដឹកស្រូវគេហា ខ្ញុំសែងបាវស្រូវហា ជំនាន់អាបាវ បាវខ្មៅហើមធំៗហា។

កៈ ចាស។

ខៈ ខ្ញុំចាប់សែងដៃជាមួយគេហា។

កៈ អញ្ចឹងអើ បង?

ខៈ សែងដៃដើម្បីយក។

កៈ ធ្វើការតាំងពីក្មេងមក?

ខៈ ចាស។

កៈ ហ្អេរ?

ខៈ ខ្ញុំនឹកឃើញថាខែបុណ្យខែទានអីម៉ែអត់មានលុយអោយ អញ្ចឹងខ្ញុំត្រូវទៅស៊ីឈ្នួលដឹកស្រូវគេ។

កៈ ចាសបង។

ខៈ ដឹកស្រូវគេខ្ញុំលើកបាវស្រូវហា បាវខ្មៅធំៗហាណា ប៉ាវម៉ាត់ហា។

កៈ ចាស។

ខៈ ខ្ញុំចាប់ដៃសែងដាក់លើរទេះហា។

កៈ ចាសបង។

ខ៖ ដល់ថ្នាក់ក្រឡាប់រទេះក្រឡាប់អីក៏មានដែរ?

ក៖ ហ្អរ មានគ្រប់បែបយ៉ាង ហិហិហិ?

ខ៖ លើករទេះតែពីនាក់ក៏មានដែរ។

ក៖ ចាស។

ខ៖ ក្រឡាប់រទេះហ្នឹងហា។

ក៖ ចាសបង។

ខ៖ ហើយខ្ញុំមានគោហ្នឹងស្លូតហា ខ្ញុំក្រឡាប់រទេះទៅហា ខ្ញុំធ្លាក់នៅក្រោយគោហ្នឹង គោហ្នឹងអត់បោលទេឈប់មង។

ក៖ ហ្អរ?

ខ៖ ចាស។

ក៖ នាក់ខ្លះខ្លាចហា គោជាន់គោអីអញ្ចឹង។

ខ៖ អត់ ហ្វខ្ញុំទៅឃ្វាលគោ។

ក៖ ចាស។

ខ៖ ឃ្វាលគោ គោខ្ញុំ ខ្ញុំដឹកគោទៅឃ្វាលហា ពេលហ្នឹងគោវាជល់គ្នារហ្អរ។

ក៖ ចាស។

ខ៖ គោ ពួកគោឈ្មោលៗហ្អេ តែវាឃើញវាដេញគ្នារហើយ។

ក៖ ចាស។

ខ៖ តែគោខ្ញុំស្លូតទេ អត់ចេះដេញគេហ្អេ គោគេមកដេញមង ហើយខ្ញុំដឹកអញ្ចឹងហា ខ្ញុំអត់ដឹងទេ ដឹកគោ គោមួយមុខគោមួយក្រោយ ដល់តែពេលគោគេឃើញគោខ្ញុំហា វាដេញចូលមកអាគោពីក្រោយហ្នឹងរត់បុកខ្ញុំហា គេថាខ្ញុំស្លាប់ហើយ។

ក៖ ចាស។

ខ៖ ដំពេលនេះ។

ក៖ អត់អី?

ខ៖ ខ្ញុំងើបមកអត់មានអី ហើយគេស្ទើចខ្ញុំគ្រប់គ្នារ។

ក៖ ហ្អេរ?

ខ៖ គោជាន់ទាំងពីហា។

ក៖ ចាស។

ខ៖ មកពីក្រោយមកហា មួយទំហឹងហើយដំតែពេលខ្ញុំងើបមកដូចអត់មានឈឺអីអត់មានកើតអីអញ្ជឹង។

ក៖ ចាស។

ខ៖ ឡើងគេនាក់ដឹកគោជាមួយគ្នារហ្នឹង ចាស់ៗហាគាត់ស្ទើចហា គាត់ថាមិញឃើញឯងគោជាន់មួយទំហឹងហា  ហើយគោឡើងពីហើយបោលពីចំងាយទៀតបុក។

ក៖ ហើយអត់អី?

ខ៖ អត់អី។

ក៖ ចាស។

ខ៖ គោតែពេលវាបោលអញ្ជឹងកំលាំងខ្លាំងហា។

ក៖ ចាស។

ខ៖ គោឈ្មោលៗ ហើយធំៗហា គោខ្ញុំហា លិចៗក្បាល។

ក៖ ចាស។

ខ៖ ព្រោះឪខ្ញុំនាក់រកស៊ីគោ ដំពេលអញ្ជឹងអាណាល្អៗគាត់ទុក។

ក៖ ចាសបង។

ខ៖ ចាស។

ក៖ ហើយបងអើ តាំងពីក្មេងរហូតមកដល់ឥឡូវសព្វថ្ងៃហា បងឃើញថាជីវិតបងមានការផ្លាស់ប្តូរអីខ្លះហ្អេស?

ខ៖ ខ្ញុំមានការផ្លាស់ប្តូរច្រើន ដោយសារខ្ញុំមានគ្រួសារទៅ ក្រុមគ្រួសារគាត់អើ គាត់ខំប្រឹងដើម្បីក្រុមគ្រួសារ កូនចៅយើងដើម្បីបានរីកចំរើន គាត់អត់ចង់អោយអាភាពក្រីក្រពីមុនវាមានហា។

ក៖ ចាសបង។

ខ៖ ចាស ខ្ញុំរីកចំរើនខ្លាំង ច្រើនមែនទែនហើយក៏ខ្ញុំជួយបងប្អូនបានច្រើនដែរ។

ក៖ ចាស។

ខ៖ អាភាពក្រីក្រហ្នឹង វាអត់ចង់អោយមានហា ដោយសារខ្ញុំខំប្រឹងតស៊ូពិបាកពីមុនមកហា។

ក៖ ចាសបង។

ខ៖ ពិបាកច្រើន។

ក៖ អញ្ចឹងបងផ្លាស់ប្តូរទាំងជីវភាព?

ខ៖ ចាស។

ក៖ ទាំងអារម្មណ៍?

ខ៖ អារម្មណ៍។

ក៖ ហ្នឹងហើយ ប្តូទាំងអស់?

ខ៖ ហ្នឹងអើ វាមានភាពរីកចំរើនច្រើនមែនទែន។

ក៖ ចាសបង។

ខ៖ ចាស។

ក៖ ហើយបងចូលចិត្តញាំម្ហូបប្រភេទណាដែរ?

ខ៖ ខ្ញុំចូលចិត្តអាររបៀបស្រែៗច្រើន។

ក៖ ម្ហូបស្រុកស្រែចំការ?

ខ៖ ហើយបើប្តីខ្ញុំគេចូលចិត្តរបៀបអឺរ៉ុប។

ក៖ ហិហិហិ។

ខ៖ ហើយកូនខ្ញុំគេចូលចិត្តអឺរ៉ុបដែរ។

ក៖ ចាស ហើយបងចេះធ្វើ?

ខ៖ ខ្ញុំចេះធ្វើតាម ដោយតាមគាត់ដែរ។

ក៖ ហ្អរ?

ខ៖ ហើយនឹងទៅហាងតាមគាត់ទៅ មើលគេទៅរបៀបគេទៅ ចេះតែឆ្លាតបានចេះធ្វើដែរហ្នឹងហា។

ក៖ ចាសបង។

ខ៖ អោយតែខ្ញុំបានទៅញាំអញ្ចឹងមកវិញគឺខ្ញុំរៀនធ្វើហើយ។

ក៖ ចាសចាស។

ខ៖ ខ្ញុំចង់ដឹង ចង់ដឹងចង់ឃើញចង់ចេះធ្វើ។

ក៖ ចាសបង។

ខ៖ អញ្ចឹងខ្ញុំទៅញាំរបស់គេ គឺមកវិញខ្ញុំរៀនធ្វើហើយ។

ក៖ ចាសបង។

ខ៖ អោយតែរបស់ណាភ្លែក។

ក៖ ចាស ហើយចុះល្បែងប្រជាប្រិយ៍វិញ បងចូលចិត្តលេងល្បែងប្រជាប្រិយ៍ប្រភេទណាដែរ?

ខ៖ ហ្អេរ ល្បែងប្រជាប្រិយ៍ថាគឺច្រើនណាស់លេង កាលពីនៅតូចៗខ្ញុំចូលចិត្ត។

ក៖ នៅក្មេងៗហិហិហិ។

ខ៖ ចាស នៅតូចៗចូលចិត្តលេងអាស្វាដណ្តើមទីហ្អេរ។

ក៖ ចាសចាស។

ខ៖ ស្វាដណ្តើមទី ហើយអើ អាស្អីស្លឹក ស្លឹកអើ ដេញចាប់ស្លឹកឈើហ្អេរ?

ក៖ អើ ដណ្តើមស្លឹកឈើ។

ខ៖ ដណ្តើមស្លឹកឈើហ្នឹងហើយដណ្តើមស្លឹកឈើ។

ក៖ ចាស។

ខ៖ ខ្ញុំចូលចិត្តលេងអាហ្នឹង។

ក៖ ចាសបង។

ខ៖ ហើយបើនៅសាលារៀនវិញហា ចូលចិត្តលោតកៅស៊ូហា។

ក៖ ហិហិហិ។

ខ៖ កំពស់ណាក៏ខ្ញុំលោតផុតដែរ។

ក៖ ខ្ញុំចូលចិត្តដែរ ហិហិហិ។

ខ៖ ចាស ហូ ពិនណាស់អារឿងលោតកៅស៊ូ។

ក៖ ចាសបង ហើយចុះចម្រៀងវិញ បងចូលចិត្តចម្រៀងប្រភេទណាដែរ? សម័យបុរាណ ភ្លេងការឬក៏អីអញ្ចឹងហា?

ខ៖ អើ ខ្ញុំចូលចិត្តភ្លេងការ ហើយចូលចិត្តស្តាប់ហើយចូលចិត្តច្រៀងទៀត អើប្រហែលខ្ញុំនៅកាលប្រាំពីប្រាំបីដន្តប់ខ្ញុំចូលចិត្តច្រៀងភ្លេង ភ្លេងការហា។

កៈ ចាសបង។

ខៈ ចូលចិត្ត។

កៈ ចាសចាស ចុះនៅអើ ក្នុងក្រុមគ្រួសារបងមានណាគេចេះលេងឧបករណ៍ភ្លេងហ្អេ?

ខៈ ខ្ញុំមានអើ ក្មួយអើ ក្មួយរបស់ប៉ាខ្ញុំ។

កៈ ចាស។

ខៈ ដូចជាចង់ទៅថៅហើយមិនមែនជាក្មួយទេ កូនអើ កូនរបស់អើ ក្មួយគាត់។

កៈ ចាស។

ខៈ ហ្នឹងហៅថៅវិញហើយ។

កៈ ចាស។

ខៈ ហ្នឹងគាត់លេងភ្លេងការ។

កៈ ហ្អរ?

ខៈ ចាស គាត់នាក់លេងភ្លេង។

កៈ លេងភ្លេងការ?

ខៈ ចាស។

កៈ អញ្ចឹងបានបងចូលចិត្តភ្លេងការ?

ខៈ ចូលចិត្ត ហិហិហិ។

កៈ ហិហិ ចុះអើ ផ្ទះរបស់បងកាលបងរស់នៅជាមួយហ្នឹងឪពុកម្ដាយហា? មានលក្ខណះមិចដែរបង? ជាផ្ទះថ្មឬក៏ឈើ?

ខៈ កាលហ្នឹងរស់នៅដំបូងផ្ទះឈើ។

ក៖ ហ្អេរ?

ខ៖ ផ្ទះឈើហ្នឹងបាំងសាំងឬស្សីមួយចំហៀងក្តារមួយចំហៀងអញ្ចឹងទៅណា។

ក៖ ចាស។

ខ៖ ហើយអត់អើ អត់ផ្ទះខ្ពស់ទេ ផ្ទះទាមអារបៀបលើកផ្ទើហា។

ក៖ ចាសបង។

ខ៖ ប៉ុន្តែអើ ប្រក់ដំបូងក្បឿង ក្បឿងខ្មែរ។

ក៖ ចាសបង។

ខ៖ ក្បឿងខ្មែរហ្នឹងវាមានបែកអញ្ចឹងហាណា ដំពេលភ្លៀងមកស្រក់ទក់ៗអញ្ចឹងទៅណា ដើរត្រងតែអាទរហ្នឹង ភ្លៀងហើយមិនដើរត្រងអញ្ចឹងហើយ។

ក៖ ចាសបង។

ខ៖ ដើរត្រង។

ក៖ ចាស ហើយចុះអើ ផ្ទះហ្នឹងអើ ជួលជាងសាងសង់ឬក៏ឪពុកម្តាយបងសាងសង់ខ្លួនឯង?

ខ៖ គាត់អើ ដូចគេហៅផ្ទះអើ ផ្ទះបាយពលពតហា។

ក៖ ហ្អេរ សល់មក?

ខ៖ ជំនាន់ពលពតហា។ ចាស សល់ពីជំនាន់ពលពតមកគាត់នៅរហូតអញ្ចឹងហា។

ក៖ ហ្អេរ ចាសបងចាស។

ខ៖ ចាស។

ក៖ ហើយចុះសំរាប់បង តើបងមានជំនាញណាដែរបងចេះតមកពីឪពុកម្តាយ? ឬក៏តាយាយជីដូនជីតាបងហ្អេស?

ខ៖ ដូចអត់មានអីផងហ្នឹង។

ក៖ អត់មានជំនាញចេះទេ?

ខ៖ អត់មានជំនាញខាង មានតែធ្វើស្រែធ្វើអីហ្នឹង។

ក៖ ចាស។

ខ៖ ជំនាញខ្ញុំ។

ក៖ ចាស អាហ្នឹងក៏ជំនាញដែរ។

ខ៖ ចាស។

ក៖ តៗគ្នារហ្នឹងហា។

ខ៖ ចាស តហ្នឹងហើយ។

ក៖ ចាស ហើយចុះតើបងអាចប្រាប់ខ្ញុំបានហ្អេ? ថាពេលណាដែរបងលំបាកជាងគេនៅក្នុងជីវិតរបស់បង?

ខ៖ លំបាកបំផុត បំផុតអាហ្នឹងនៅពេលដែរខ្ញុំនៅស្រុកធ្វើស្រែហា។ ខ្ញុំយ៉ាប់ហា។

ក៖ ចាស។

ខ៖ ខ្ញុំយ៉ាប់ហើយខ្ញុំចង់ថាអោយដោះភាពក្រីក្រហ្នឹង ខ្ញុំមានតែពាក្យហ្នឹងថារំដោះអា រំដោះអាភាពក្រីក្រហ្នឹងទាល់តែបាន។

ក៖ ចាសបង។

ខ៖ ក្នុងចិត្តខ្ញុំ។

ក៖ ចាស។

ខ៖ ចាស។

ក៖ ហើយបងក៏ធ្វើវាបានសំរេច?

ខ៖ ចាស ខ្ញុំធ្វើវាបានសំរេច។

កៈ ដោយសារបងតស៊ូ?

ខៈ តស៊ូ។

កៈ ចាសបង។

ខៈ ចាស ភាពតស៊ូទំរាំបានប៉ុណ្ណឹងខ្ញុំនៅផ្ទះគេឡើងឆ្អែតហើយ។

កៈ ចាសបង។

ខៈ នៅតាំងពីមើលកូនគេ មកដល់ដាំបាយអោយគេហូប ហើយខ្ញុំមានភាពតស៊ូហា ផ្ទះគេបោកអ៊ុតហា។

កៈ ចាសបង។

ខៈ ខ្ញុំងើបដាំបាយលក់ខ្ញុំអើ លក់ផងបាយផងអើ គេអោយខ្ញុំអើ បោកអ៊ុតផង។

កៈ ចាស។

ខៈ ចាស គឺកិច្ចការក្នុងផ្ទះហ្នឹងប៉ុន្មានខ្ញុំធ្វើបានទាំងអស់ គេលក់ចាប់ហួយលក់អីខ្ញុំលក់បានទាំងអស់។ ហើយខោអាវដូចថាគេបោកគេថ្ងៃហ្នឹង គេយកវិញល្ងាច ខ្ញុំធ្វើបានទៀត។

កៈ ចាស។

ខៈ ចាស។

កៈ បងបានឆ្លងកាត់មកបាន។

ខៈ ចាស ចាស។

កៈ អញ្ចឹងពេលបង ពេលយើងរីកចំរើនយើងនឹងមានឱកាសជួយនាក់ដ៏ទៃ?

ខៈ ចាស យល់ហា។

កៈ យល់ពីអារម្មណ៍របស់នាក់ដ៏ទៃហា។

ខៈ យល់ហ្នឹងហើយ។

កៈ ចាសបង។

ខៈ ដោយសារយើងមានភាពក្រីក្រពីមុនមកហា។

កៈ ចាសបង ហើយអើ សំរាប់បទពិសោធន៍ដែរសប្បាយវិញ តើបងគិតថាពេលណាដែរបងសប្បាយជាងគេក្នុងជីវិតបង?

ខៈ សប្បាយជាងគេគឺប្តីធ្វើអោយសប្បាយចិត្ត ហិហិហិ។

កៈ ហិហិហិ។

ខៈ ការនាំដើរលេង។

កៈ ចាស។

ខៈ គាត់នាំដើរលេងអញ្ចឹងទៅណា។

កៈ ចាសបង។

ខៈ ទៅលេងដូចជាទៅកំពង់សោមទៅអីអញ្ចឹងទៅណា គាត់ចង់អោយយើងសប្បាយអញ្ចឹងទៅ គាត់នាំទៅដើរទៅក្រៅអីអញ្ចឹងទៅ បានយើងថាអោយ អោយយើងសប្បាយចិត្តដែរ នាំទៅថៃទៅអីអញ្ចឹងទៅណា។

កៈ ចាសបង។

ខៈ ទៅវៀកណាមទៅអីហ្នឹង គាត់ចង់អោយយើងមានភាពសប្បាយ។

កៈ ចាស។

ខៈ អញ្ចឹងខ្ញុំអរគុណគាត់ដែរហ្នឹងហា គាត់បានធ្វើអោយយើងមានភាពសប្បាយច្រើនណាស់។

កៈ ចាសបងចាស។

ខៈ គាត់ស្រឡាញ់កូនចៅណាស់។

កៈ ចាស។

ខ៖ ចាស។

ក៖ ហើយអើ កាលពីបងនៅក្មេងៗហា រហូតមកដល់ឥឡូវ តើបងធ្លាប់មានក្ដីស្រមៃឬក៏បំណងប្រាថ្នាអីទៅថ្ងៃអនាគតហ្អេស?

ខ៖ មានក្ដីស្រមៃ ខ្ញុំចង់ខ្ញុំឃើញគេ ដូចថាអើ ខ្ញុំមានតែបងប្អូននៅស្រុកស្រែ ខ្ញុំឃើញគេនៅភ្នំពេញហា ខ្ញុំចង់ ហើយខ្ញុំចង់មកនៅហា។

ក៖ ចាស។

ខ៖ កាលពីមុនខ្ញុំនៅតូចហា ខ្ញុំគិតថាចេះ ខ្ញុំថាខ្ញុំមិនដឹងថាខ្ញុំធ្វើមិចទេ បាននៅទីក្រុងហ្នឹងគេ ឃើញគេនៅភ្នំពេញនៅអីអញ្ចឹង ដូចថាគេ មើលទៅដូចគេអស្ចារ្យណាស់។

ក៖ ចាស។

ខ៖ កាលនៅតូចហា។

ក៖ ចាស។

ខ៖ កាលជំនាន់ហ្នឹងឃើញអោយតែនាក់ភ្នំពេញទៅហា ហើយនៅជនបទហ្នឹងរោមមើលគេហើយ។

ក៖ ចាស មាននំប៉ុងផ្ញើរ។

ខ៖ ហ្នឹងហើយ ថាអើយ សប្បាយណាស់ ដំគេទៅហ្នឹងគេមាននំប៉ុងផ្ញើរ ហើយឃើញគេមានភាពស្អាតអីអញ្ចឹងហា។

ក៖ ចាស។

ខ៖ យើងនាក់ស្រែអត់មានភាពស្អាតហា យើងថាដូចថាឃើញគេមកដល់ដៃជើងគេស្អាតអញ្ចឹងហា ហើយយើងឃើញមកដូចអារបៀបនាក់ស្រែហា ដៃជើងសិទ្ធតែដីសិទ្ធតែផក់អីអញ្ចឹងទៅណា។

ក៖ សិទ្ធតែផក់ ចាស។

ខ៖ ហើយស្លៀកពាក់ខោអាវដូចអត់បានស្អាតតាមគេទេ។

ក៖ ចាសបង។

ខ៖ ជំនាន់ខ្ញុំហា អាវសុទ្ធតែប៉ាស់ហ្នឹង។

ក៖ ចាស។

ខ៖ ដេររហែកដេរប៉ះបំណាស់យកមកពាក់។

ក៖ ចាសបងចាស។

ខ៖ ចាស។

ក៖ តែឥឡូវជីវិតបងក៏ផ្លាស់ប្តូ?

ខ៖ ផ្លាស់ប្តូបានច្រើន។

ក៖ ចាសបង។

ខ៖ ចាស។

ក៖ ហើយជាចុងក្រោយ បងមានឱកាសដើម្បីផ្តាំផ្ញើរដល់កូនចៅជំនាន់ក្រោយៗទៀតរបស់បង។ តើបងចង់និយាយអ្វីខ្លះទៅកាន់ពួកគាត់? ហើយចង់អោយគាត់មានភាពជោកជ័យអីខ្លះក្នុងជីវិត?

ខ៖ ចាស ខ្ញុំផ្តាំចង់អើ ខ្ញុំផ្តាំផ្ញើរកូនខ្ញុំទាំងបីអោយមានភាពក្លាហាន ហើយនឹងដើម្បីអោយពួកគាត់ខំរៀនដើម្បីៗជួយដល់ក្រុមគ្រួសារ ចង់អោយគាត់រីកចំរើន ដូចថាអើ ខ្ញុំឃើញគេ កូនគេរៀនជ្រៅជ្រះដោយសារគេខំរៀនអញ្ជឹងហា ហើយចំពោះខ្ញុំអត់បានរៀនជ្រៅជ្រះ ដ៏អញ្ជឹងខ្ញុំចង់អោយកូនខ្ញុំរៀនអោយចេះដឹង។

ក៖ ចាស។

ខ៖ បានប្រាក់ខែច្រើនដើម្បីអោយគេចញ្ចឹមខ្លួនគេ។

ក៖ ចាសបង។

ខ៖ ចាស ហ្នឹងហើយខ្ញុំអត់ដឹងថាខ្ញុំចញ្ចឹមគេបានប៉ុនណាខ្ញុំអត់ទាន់ដឹងហា។

ក៖ ចាស។

ខ៖ ហើយខ្ញុំចង់អោយកូនមកព្រះវិហារអោយទៀងទាត់ អោយគាត់មកកាន់ព្រះវិហារដើម្បីអោយស្គាល់ក្នុងព្រះ។

ក៖ ចាស។

ខ៖ អោយដូចថា ដូចប៉ាគាត់ហា។

ក៖ ចាស។

ខ៖ ចាស មានពាក្យប៉ុណ្ណឹង។

ក៖ ហើយចង់អោយគាត់ក្លាយជាមនុស្សបែបណាដែរ?

ខ៖ ចាស ចង់អោយគាត់ជាមនុស្សល្អមួយដែររស់នៅក្នុងសង្គមដែរគេរាប់អានអញ្ចឹងហា។

ក៖ ចាស។

ខ៖ ដូចជាគំរូគេដែរ។

ក៖ ចាសបងចាស។

ខ៖ ចាស។

ក៖ ចាស បងអស់ហើយ?

ខ៖ អស់ហើយ។

ក៖ ចាសបង អញ្ចឹងអរគុណច្រើនមែនទែនបង ដែរបានចំណាយពេលអើ ដ៏មានតម្លៃរបស់បងដើម្បីចែកចាយនឹងពិភាក្សាអំពីប្រវត្តិផ្ទាល់ខ្លួនរបស់បង។

ខ៖ ចាស។

កៈ ហើយបងបន្ទាប់ពីខ្ញុំយកអើ សំភាសន៏បងហើយខ្ញុំនឹងយកសំលេងរបស់បងដាក់ចូលទៅក្នុងវេបសាយ៏របស់សាលា BYU ដែរមានឈ្មោះថា www.cambodaioralhistrice.byu.edu អញ្ចឹងតើបងអនុញ្ញាតិដើម្បីអោយខ្ញុំយកសំលេងរបស់បងដាក់ចូលទៅក្នុងវេបសាយ៏របស់សាលា BYU ហ្អេសបង?

ខៈ ចាសបាន។

កៈ ចាស អញ្ចឹងអរគុណច្រើនបង។

ខៈ ចាសចាស។

កៈ ហើយខ្ញុំដឹងថាអ្វីដែរបងបានចែកចាយវាហ្នឹងមានប្រយោជន៏ដល់កូនចៅជំនាន់ក្រោយៗទៀតរបស់បង ដើម្បីពួកគាត់អាចមានឱកាសរៀនហើយស្តាប់ពាក្យផ្តែផ្តាំរបស់បង ហើយគាត់នឹងអាចដឹងនៅអ្វីដែរពួកគាត់ត្រូវធ្វើបន្តទៅមុខទៀតនៅក្នុងជិវិតរបស់គាត់ហាបង។

កខៈ ចាស។

កៈ ចាស អញ្ចឹងអរគុណច្រើនបង៕